# កម្មវិធីសន្ទនាតាមវិទ្យុ

# “ស្វែងយល់ពីច្បាប់សំខាន់ៗដែលជាឧបករណ៍លើកកំពស់ អភិបាលកិច្ចល្អ”

*សម្រាប់ថ្ងៃច័ន្ទ ទី ៦ ខែ មិថុនា ឆ្នាំ ២០១១*

**ចំនួនអត្ថបទ:** ៣៣២ អត្ថបទ

***ដំណឹងសំខាន់ៗប្រចាំសប្តាហ៍:*** *០៣ ដំណឹង*

## ១. *ប្រជាពលរដ្ឋតវ៉ាអំពីកុងត្រូលជជុះ ស្ទាក់ចាប់រថយន្តលើកំណាត់ផ្លូវជាតិលេខ ៦*

តាមកាសែត ***កោះសន្តិភាព*** ចេញផ្សាយថ្ងៃទី ២ មិថុនា បានឱ្យដឹងថា ក្រុមអ្នករត់តាក់ស៊ី និងអ្នកធ្វើដំណើរ បានរិះគន់ថាមានកុងត្រូលជជុះ ពី៥ទៅ៨កន្លែង បានដាក់ពង្រាយតាមដងផ្លូវជាតិលេខ៦ បណ្តាក់ដូចខ្សែចាប់ពីស្រុកបារាយណ៍រហូតដល់ស្រុកស្ទោង ហើយប្រសិនបើឃើញរថយន្តជនសង្ស័យណាមួយនោះ គេនឹងបើករថយន្តដេញតាមព្រោះក្រែងមានផ្ទុកឈើឬសត្វព្រៃ និងសូម្បីតែរថយន្តដឹកអ្នកដំណើរធម្មតាក៏ត្រូវហៅឱ្យឈប់ដើម្បីឆែកឆេរដែរ។ អ្នករត់តាក់ស៊ីកំពង់ចាម-សៀមរាប ម្នាក់ និយាយថា នៅរាល់ពេលដឹកអ្នកដំណើរចេញពីក្រុងកំពង់ចាមទៅកាន់ខេត្តសៀមរាប សម្រាប់ទឹកដីខេត្តកំពង់ធំ ចាប់តាំងពីស្រុកបារាយណ៍រហូតដល់ស្រុកស្ទោង មានកុងត្រូលជជុះជាច្រើនកន្លែង ហើយសូម្បីតែរថយន្តដែលមានឯកសារគ្រប់គ្រាន់ទៅហើយក្តី ក៏គេហៅឱ្យឈប់ទារលុយយ៉ាងហោចណាស់១កន្លែង អស់ចំនួន៥០០០រៀល ដែរ ទើបអនុញ្ញាតឱ្យបន្តដំណើរទៅមុខទៀត។ ***កោះសន្តិភាព*** បានដកស្រង់ប្រសាសន៍លោកឧត្តមសេនីយ៍ ហុង ថុល មេបញ្ជាការកងរាជអាវុធខេត្តកំពង់ធំ ដែលមានប្រសាសន៍តាមទូរស័ព្ទថា នៅក្រុងស្ទឹងសែន អាជ្ញាធរខេត្តបានបង្កើតគណៈកម្មការចំរុះមួយរួមមានរដ្ឋបាលព្រៃឈើ អាវុធហត្ថ និង នគរបាល ដើម្បីបង្ក្រាបបទល្មើសព្រៃឈើ។ ចំពោះហេតុការណ៍ដែលថាមានមន្ត្រីរាជអាវុធហត្ថ និងនគរបាល បើករថយន្តដេញតាមឆែកឆេររថយន្តរបស់អ្នកដំណើរនោះ រូបលោកបានបញ្ជាក់ថាមិនមាននោះទេ។ ក្រៅពីនេះ មានក្រុមត្រួតពិនិត្យសុវត្ថិភាពចរាចរណ៍ផ្លូវគោក ដែលមានអាវុធហត្ថ នគរបាលចរាចរ និងមន្ត្រីសាធារណការខេត្ត តែងតែដាក់ចល័តម្តងត្រង់នេះម្តងត្រង់នោះ ដើម្បីពង្រឹងច្បាប់ចរាចរណ៍ ចំណែកកុងត្រូលជជុះ ដែលចេញឆ្នក់តាមដងផ្លូវនោះ គឺមិនឃើញមានឡើយ។

## ២. *ពលរដ្ឋមកពី២០រាជធានី-ខេត្ត ដែលមានបញ្ហាវិវាទដីធ្លី ជួបជុំគ្នាថ្លែងពីទុក្ខកង្វល់របស់ខ្លួន*

សារពត៌មានជាច្រើនបានចុះផ្សាយព្រមៗគ្នា នូវពត៌មានស្តីពីប្រជាពលរដ្ឋដែលមានបញ្ហាដីធ្លី មកពី២០ រាជធានី-ខេត្ត មកជួបជុំគ្នានៅរាជធានីភ្នំពេញ ដើម្បីថ្លែងពីទុក្ខកង្វល់របស់ខ្លួន ហើយបានស្នើឱ្យរាជរដ្ឋាភិបាលជួយដោះស្រាយ។ កាលពីព្រឹកថ្ងៃទី២ មិថុនា មានការបើកសន្និសីទសារព័ត៌មានមួយ នៅទីស្នាក់ការសមាគមអាដហុក ដោយមានការចូលរួមពីប្រជាពលរដ្ឋជាច្រើននាក់ ដែលមានបញ្ហាវិវាទដីធ្លី។ កាសែត ***កម្ពុជាថ្មី*** ចេញផ្សាយថ្ងៃទី៣ មិថុនា បានដកស្រង់សេចក្តីរាយការណ៍របស់សមាគមអាដហុក ចុះផ្សាយថា មកទល់ពេលនេះ មានប្រជាពលរដ្ឋមានបញ្ហាទំនាស់ដីធ្លី ចំនួន១២៤នាក់ ដែលត្រូវបានតុលាការចេញដីកាកោះហៅ

និងចោទប្រកាន់ពីបទព្រហ្មទណ្ឌ ក្នុងនោះមាន៦នាក់ត្រូវបានចាប់ខ្លួន ហើយ១៨នាក់កំពុងជាប់ឃុំឃាំងក្នុងពន្ធនាគារ និង ៨៨នាក់ទៀត កំពុងរត់គេចពីការតាមចាប់ខ្លួនរបស់តុលាការ ។ សេចក្តីថ្លែងការណ៍របស់សមាគមអាដហុកបានកត់សំគាល់ថា អ្នកភូមិដែលទទួលរងការចោទប្រកាន់ភាគច្រើនជាម្ចាស់ដីបានកាន់កាប់ដី ឬផ្ទះសំបែងស្របច្បាប់ ទទួលស្គាល់ដោយអាជ្ញាធរ តែត្រូវអ្នកមានអំណាច ឬថៅកែក្រុមហ៊ុន ចូលទៅកាន់កាប់ទន្ទ្រានយកមកធ្វើការកម្មសិទ្ធិ។ តំណាងប្រជាពលរដ្ឋដែលបានចូលរួមក្នុងសន្និសីទសារព័ត៌មានរបស់សមាគមអាដហុកនាព្រឹកនោះ បានសំដែងក្តីបារម្ភចំពោះសុវត្ថិភាពផ្ទាល់ខ្លួន ដោយសារតែពួកគាត់កំពុងតែស្ថិតក្នុងការតាមចាប់ខ្លួនរបស់សមត្ថកិច្ចក៏ដូចជាតុលាការ នឹងបានស្នើឱ្យរាជរដ្ឋាភិបាលក៏ដូចជាស្ថាប័នពាក់ព័ន្ធ ជួយដោះស្រាយពួកគាត់ឱ្យបានចប់ដើម្បីឱ្យពួកគាត់រស់នៅនិងប្រកបមុខរបរចិញ្ចឹមជីវិត។ តំណាងប្រជាពលរដ្ឋបានលើកឡើងផងដែរ អំពីភាពអយុត្តិធម៌បង្កឡើងដោយភាគីម្ខាង ហើយត្រូវបានពួកគាត់ចោទប្រកាន់ថាជាអ្នកមានអំណាចឬថៅកែក្រុមហ៊ុនជាដើម ហើយរាល់ការប្តឹងនានា ពួកគាត់មិនដែលទទួលបានជ័យជំនះឡើយ។***កម្ពុជាថ្មី*** បញ្ជាក់ថា មិនទាន់មានការឆ្លើយតបពីអាជ្ញាធរដោះស្រាយវិវាទដីធ្លីចំពោះបញ្ហានេះនៅឡើយទេ។ ប៉ុន្តែកន្លងមក មន្ត្រីរាជរដ្ឋាភិបាលធ្លាប់បានលើកឡើងថា រាជរដ្ឋាភិបាលបានមានវិធានការរួចហើយ ដើម្បីដោះស្រាយបញ្ហាជំលោះដែលកំពុងកើតមាន។ ចំណែកឯកឧត្តម ឱម យ៉ិនទៀង ទេសរដ្ឋមន្ត្រី និងជាប្រធានអង្គភាពប្រឆាំងអំពើពុករលួយ ក៏ធ្លាប់មានប្រសាសន៍ដែរថាលោកនឹងសហការជាមួយសមាគមអាដហុក ដើម្បីចុះទៅដោះស្រាយបញ្ហាដីធ្លី។

### ៣. *ក្រុមអតីតយុទ្ធជននៅខេត្តសៀមរាប ផ្ទុះការតវ៉ាដោយសារបាត់ប្រាក់ខែរយៈពេល១ឆ្នាំ*

យ៉ាងហោចណាស់ក៏មានសារពត៌មានជាតិធំៗចំនួនពីរដែរ គឺ *រស្មីកម្ពុជា* និង *កម្ពុជាថ្មី* បានចុះផ្សាយដំណឹងស្តីអំពីការតវ៉ារបស់ក្រុមអតីតយុទ្ធជននៅខេត្តសៀមរាប និងក្រុមគ្រួសារ អំពីការមិនបានបើកប្រាក់ខែ អស់រយៈពេលដ៏យូរមកហើយ។ តាម ***កម្ពុជាថ្មី*** ចេញផ្សាយថ្ងៃទី៣ មិថុនា បានឱ្យដឹងថា អតីតយុទ្ធជននិងក្រុមគ្រួសារ ប្រមាណជាង១០០នាក់ ពីគ្រប់បណ្តាស្រុក នៃខេត្ត សៀមរាប បាននាំគ្នាធ្វើដំណើរទៅកាន់មន្ទីរសង្គមកិច្ចខេត្ត ដើម្បីធ្វើការសាកសួរអំពីរឿងបាត់ប្រាក់ខែរបស់ពួកគាត់ រយៈពេលមួយឆ្នាំកន្លងមក។ សកម្មភាពផ្ទុះការតវ៉ានេះ កើតឡើងកាលពីថ្ងៃទី៣១ ឧសភា រហូតដល់ថ្ងៃទី២ មិថុនា នៅមន្ទីរសង្គមកិច្ច ក្នុងបុរីរដ្ឋបាលខេត្តសៀមរាប។ ក្រុមអតីតយុទ្ធជនទាំងអស់ដែលឡើងទៅធ្វើការតវ៉ារឿងបាត់ប្រាក់ខែនេះ បានសម្តែងការខកចិត្តយ៉ាងពន់ពេក នៅពេលដែលពួកគាត់មួយចំនួន បើកប្រាក់ខែមិនបាន ដោយសារតែខាងមន្ត្រីទទួលកិច្ចការនេះ ប្រាប់ថាឈ្មោះរបស់អតីតយុទ្ធជនមួយចំនួនត្រូវបានកាត់ចេញពីបញ្ជីបើកប្រាក់ខែ។ ទោះជាយ៉ាងណាក៏ដោយ ***កម្ពុជាថ្មី*** បានដកស្រង់ប្រសាសន៍លោក សឹង ម៉ុន អគារធិការស្តីទីនៃក្រសួងសង្គមកិច្ច ទទួលបន្ទុកកិច្ចការនេះ បានឱ្យដឹងថា ជាគោលការណ៍ ថ្នាក់លើបានបញ្ឈប់ការបើកប្រាក់ខែនេះតាំងពីខែមិថុនា ឆ្នាំ២០១០ មិនមែនខាងមន្ទីរឬខាងណាមួយកឹបកេងប្រាក់ខែរបស់បងប្អូននោះទេ។ លោកបន្តថាដោយសារតែបងប្អូនមិនបានដឹងពីគោលការណ៍នេះ ទើបនាំគ្នាមកធ្វើការចោទប្រកាន់លើមន្ត្រីសង្គមកិច្ច។ ជាសេចក្តីបញ្ចប់អត្ថបទរបស់ខ្លួន ***កម្ពុជាថ្មី*** បានសរសេរបន្ថែមថា គួររំឭកថាទាក់ទិននឹងកិច្ចការសង្គមកិច្ចនេះ ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេច

អគ្គមហាសេនាបតីតេជោ ហ៊ុន សែន បានធ្វើការព្រមានធ្ងន់ៗពីរលើករួចមកហើយ ដោយសារតែស្ថាប័នមួយនេះធ្វើកិច្ចការមិនប្រក្រតីជាច្រើន ដែលជាហេតុធ្វើឱ្យប៉ះពាល់ដល់វិស័យការពារជាតិ។ សម្តេចប្រមុខរាជរដ្ឋាភិបាល ក៏បានចាត់បញ្ជាឱ្យអង្គភាពប្រឆាំងអំពើពុករលួយចាត់វិធាន ការស៊ើបអង្កេតលើករណីនេះជាបន្ទាន់ ដើម្បីបោសសម្អាតមន្ត្រីខិលខូចមួយចំនួនដែលជាត្រីងៀតឆ្អៀតពង។